00642293

E35

# អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens

ឯកសារដើម
ORIGINAL DOCUMENT/DOCUMENT ORIGINAL
ថ្ងៃ ខែ ឆ្នាំ ទទួល (Date of receipt/Date de reception): 08 / 02 / 2011
ម៉ោង (Time/Heure): 9:15
មន្ត្រីទទួលបន្ទុកសំណុំរឿង/Case File Officer/L'agent chargé du dossier: Uch Arun

## អនុស្សរណៈ - អង្គជំនុំជម្រះសាលាដំបូង

**ជូនចំពោះ:** **គ្រប់ភាគីទាំងអស់នៃសំណុំរឿង ០០២** កាលបរិច្ឆេទ: ថ្ងៃទី ០៣ ខែ កុម្ភៈ ឆ្នាំ ២០១១

**ចម្លងជូន:** លោកប្រធាន និងលោក/លោកស្រីចៅក្រមទាំងអស់នៃអង្គជំនុំជម្រះសាលាដំបូង

**ពី:** **Susan LAMB** មន្ត្រីច្បាប់ជាន់ខ្ពស់នៃអង្គជំនុំជម្រះសាលាដំបូង

**កម្មវត្ថុ:** **ការជូនដំណឹងជាមុនអំពីសេចក្តីសម្រេចរបស់អង្គជំនុំជម្រះ ទាក់ទងនឹងឯកសារដែលមានលេខ E14, E15, E9/2, E9/3, E24 និង E27**

យោងទៅលើសំណើសុំមួយចំនួនដែលកំពុងស្ថិតក្រោមចំណាត់ការរបស់អង្គជំនុំជម្រះសាលាដំបូង និងសារណាតប និងចម្លើយតបនានា ដែលមានដូចខាងក្រោមនេះ៖

- សំណើបន្ទាន់របស់មេធាវីការពារក្តី (អៀងធីរិទ្ធ និង នួន ជា) សុំឱ្យបញ្ជាក់ថ្ងៃផុតកំណត់ ដែលបានដាក់នៅថ្ងៃទី១៤ ខែមករា ឆ្នាំ២០១១ (ឯកសារលេខ E14) និងសារណាតបរបស់សហព្រះរាជអាជ្ញា (ឯកសារលេខ E14/1) និងចម្លើយតបរបស់មេធាវីការពារក្តី (ឯកសារលេខ E14/2) ។

- សំណើបន្ទាន់របស់ អៀង សារី សុំកុំឱ្យចាប់ផ្តើមថិរវេលាសម្រាប់អញ្ញត្រកម្មរហូតដល់ពេលអង្គបុរេជំនុំជម្រះបានផ្តល់សំអាងហេតុទៅលើសាលដីការបស់អង្គបុរេជំនុំជម្រះលើបណ្តឹងឧទ្ធរណ៍របស់ អៀង សារី ប្រឆាំងនឹងដីកាដំណោះស្រាយ និងសំណើជាបន្ទាន់សុំពេលវេលាបន្ថែម និងបង្កើនចំនួនទំព័រកំណត់ ដើម្បីដាក់បណ្តឹងអំពីអញ្ញត្រកម្មតាមវិធាន ៨៩ ដែលបានដាក់នៅថ្ងៃទី១៧ ខែមករា ឆ្នាំ២០១១ (ឯកសារលេខ E15) និងសារណាតបរបស់សហព្រះរាជអាជ្ញា (ឯកសារលេខ E15/1) និងចម្លើយតបរបស់មេធាវីការពារក្តី (ឯកសារលេខ E15/2)។

- សំណើរបស់មេធាវីការពារក្តី (អៀង ធីរិទ្ធ) សុំឱ្យមានការផ្លាស់ប្តូរវិធាន ៨០ នៃវិធានផ្ទៃក្នុង ដើម្បីបង្គាប់ឱ្យសហព្រះរាជអាជ្ញា ដាក់បង្ហាញនូវបញ្ជីភស្តុតាង មុនពេលមេធាវីការពារក្តីដែលត្រូវផ្តល់ឱ្យនូវបញ្ជីឈ្មោះសាក្សីបន្ថែម ដែលបានដាក់នៅថ្ងៃទី២៧ ខែមករា ឆ្នាំ២០១១ (ឯកសារលេខ E9/2) ។

- សំណើសុំរបស់ អៀង សារី សុំឱ្យអង្គជំនុំជម្រះសាលាដំបូងធ្វើការជំនុំជម្រះលើសំណុំរឿងលេខ ០០២ ដោយអនុវត្តតាមវិសោធនកម្មនីតិវិធីដែលបានស្នើសុំ និងសំណើសុំផ្អាកជាបន្ទាន់លើដីកាបង្គាប់ដើម្បីដាក់សម្ភារៈសម្រាប់រៀបចំសវនាការ ដែលបានដាក់នៅថ្ងៃទី២៨ ខែមករា ឆ្នាំ២០១១ (ឯកសារលេខ E9/3) ។

ECCC, National Road 4, Chaom Chau, Dangkao, PO Box 71, Phnom Penh, Cambodia
Tel: +(855) 023 219 814 Fx: +(855) 023 219 841 Web: www.eccc.gov.kh

- សំណើបន្ទាន់របស់មេធាវីការពារក្តី អ្នកស្រី អៀង ធីរិទ្ធ ស្នើសុំឱ្យមានការបន្ថែមពេលវេលា និងចំនួនទំព័រសម្រាប់អញ្ញត្រកម្ម ដែលបានដាក់នៅថ្ងៃទី២៥ ខែមករា ឆ្នាំ២០១១ (ឯកសារលេខ E24) ។
- (ខៀវ សំផន) សំណើសុំបន្ថែមចំនួនទំព័រកំណត់ និងពន្យារពេលសម្រាប់ករណីអញ្ញត្រកម្មបឋម ដែលបានដាក់នៅថ្ងៃទី២៨ ខែមករា ឆ្នាំ២០១១ (ឯកសារលេខ E27) ។

សំណើសុំទាំងនេះមានបំណងស្នើសុំពន្យារពេល ឬ បង្អង់នូវកាលបរិច្ឆេទចុងក្រោយសម្រាប់ដាក់បញ្ជីឈ្មោះសាក្សីតាមវិធាន៨០ និងសម្រាប់ដាក់នូវអញ្ញត្រកម្មតាមវិធាន ៨៩ បន្ថែមទៅលើសំណើមួយចំនួនដែលស្នើសុំបន្ថែមចំនួនទំព័រសម្រាប់ដាក់អញ្ញត្រកម្ម ។ សំណើផ្សេងទៀតស្នើសុំឱ្យអង្គជំនុំជម្រះចាប់ផ្តើមដំណើរការនីតិវិធីចាប់ពីការចេញនូវដីកាបង្គាប់ឱ្យភាគីដាក់សម្ភារៈ ដូចដែលមានចែងក្នុងវិធានផ្ទៃក្នុងបច្ចុប្បន្ន។

បើទោះជា សេចក្តីសម្រេចរួមមួយទាក់ទងនឹងសំណើទាំងនោះនឹងត្រូវចេញក្នុងពេលឆាប់ៗក៏ដោយ កាលបរិច្ឆេទចុងក្រោយដែលត្រូវចាប់ផ្តើមអនុវត្តមុនគេនោះគឺថ្ងៃ ច័ន្ទ ទី ១៤ ខែ កុម្ភៈ ឆ្នាំ ២០១១ ដូចដែលបានបង្ហាញនៅក្នុងសំណើ។ ក្នុងគោលបំណងដើម្បីជូនដំណឹងដល់ភាគីជាមុន និងដើម្បីសម្រួលដល់ការរៀបចំសវនាការឱ្យមានប្រសិទ្ធភាព នាងខ្ញុំបានទទួលនូវការអនុញ្ញាតិពីអង្គជំនុំជម្រះដើម្បីជូនដំណឹងដល់ភាគីជាមុនអំពីការចេញសេចក្តីសម្រេចរបស់អង្គជំនុំជម្រះលើសំណើទាំងអស់ ៖

- អនុលោមតាមដីកាបង្គាប់ឱ្យភាគីដាក់សម្ភារៈដើម្បីរៀបចំសវនាការ ដែលបានចេញដោយអង្គជំនុំជម្រះ (ឯកសារលេខ E9) រយៈពេលកំណត់ដូចមានចែងក្នុងវិធានផ្ទៃក្នុង៨០(១) និង(២) និង៨៩ គឺចាប់ផ្តើមរាប់ពីថ្ងៃ សុក្រ ទី ១៤ ខែ មករា ឆ្នាំ ២០១១ ។
- អង្គជំនុំជម្រះនឹងបដិសេធនូវរាល់សំណើ ដែលបានស្នើសុំពន្យារនូវកាលបរិច្ឆេទចុងក្រោយសម្រាប់ដាក់សម្ភារៈដើម្បីត្រៀមរៀបចំសវនាការ ។ ទោះបីជាយ៉ាងណាក៏ដោយ អង្គជំនុំជម្រះទទួលស្គាល់ថា ព្យសនកម្មអាចកើតចេញពីការខកខានរបស់អង្គបុរេជំនុំជម្រះ ក្នុងការផ្តល់នូវសំអាងហេតុទាក់ទងទៅនឹងអញ្ញត្រកម្មទាំងនោះ នៅក្នុងសាលដីការបស់ខ្លួន។ ក្នុងរយៈពេលមួយសមស្រប អង្គជំនុំជម្រះនឹងបញ្ជាក់ ថាតើសារណាបន្ថែមណាខ្លះដែលនឹងតម្រូវឱ្យដាក់ និងទទួលយក បន្ទាប់ពីអង្គបុរេជំនុំជម្រះចេញសេចក្តីសម្រេចដែលមានសំអាងហេតុពេញលេញរបស់ខ្លួន។
- អង្គជំនុំជម្រះនឹងបដិសេធនូវរាល់សំណើទាំងអស់ ដើម្បីអនុម័តយកនូវនីតិវិធីថ្មីមួយ ទៅលើនីតិវិធីដូចដែលមានចែងនៅក្នុងវិធានផ្ទៃក្នុងបច្ចុប្បន្ន។
- អង្គជំនុំជម្រះនឹងបដិសេធនូវរាល់សំណើ ដែលបានស្នើសុំបន្ថែមចំនួនទំព័រសម្រាប់ដាក់អញ្ញត្រកម្ម (១៥ ទំព័រសម្រាប់ភាសាអង់គ្លេសឬបារាំង ឬ៣០ទំព័រសម្រាប់ភាសាខ្មែរ) និងស្នើសុំឱ្យភាគីទាំងអស់បង្ហាញទឡ្ហីករណ៍ជាទម្រង់សង្ខេបខ្លីៗ។ ប្រសិនបើអង្គជំនុំជម្រះយល់ឃើញថា សារណាបន្ថែមពីភាគីមានភាពចាំបាច់

នោះអង្គជំនុំជម្រះនឹងស្នើសុំឲ្យភាគីដាក់នូវសារណាទាំងនោះក្នុងរយៈពេលមួយសមស្រប។ ឯកសារយោងនានាដែលពាក់ព័ន្ធទៅនឹងអញ្ញត្រកម្មដែលភាគីបានលើកពីមុននោះ ក៏អាចលើកឡើងបានផងដែរប្រសិនបើភាគីយល់ថាពាក់ព័ន្ធ។

អង្គជំនុំជម្រះកត់សម្គាល់ផងដែរថា ភាគច្រើននៃសំណើសុំខាងលើគឺមានលក្ខណៈដូចគ្នា ឬជាន់គ្នា។ បន្ថែមលើនេះទៀត សំណើភាគច្រើនដែលបានស្នើសុំពន្យារពេលនោះ គឺទាក់ទងទៅនឹងបញ្ហានៃការបកប្រែភាសា។ ដើម្បីកាត់បន្ថយនូវបញ្ហាទាំងនេះ អង្គជំនុំជម្រះសូមស្នើឲ្យក្រុមមេធាវីការពារក្តី ធ្វើការដាក់បញ្ចូលនូវសំណើរបស់ខ្លួនចូលទៅក្នុងសំណើរួមតែមួយ ដើម្បីដាក់នៅចំពោះមុខអង្គជំនុំជម្រះ ក្នុងករណីដែលសំណើទាំងនោះមាននូវយុត្តិសាស្ត្រដូចគ្នា ។

សូមទទួលនូវការគោរពរាប់អានដ៏ខ្ពង់ខ្ពស់អំពីនាងខ្ញុំ។